# ការសំភាសន៍របស់អ្នកមីង ដែរ ច្រឹប

កៈ អ្នកដែរសំភាសន៍ឈ្មោះ ជាងស៊ីអារ     ខៈ អ្នកដែរអោយគេសំភាសន៍ឈ្មោះដែរ ច្រឹប

## <u>ការសង្ខេបប្រវត្តិរបស់អ្នកមីងដែក ច្រឹប</u>

អ្នកមីង ដែរ ច្រឹប មានអាយុ53ឆ្នាំនៅក្នុងឆ្នាំ2018 អ្នកមីង ដែរ ច្រឹប មានភេទស្រី អ្នកមីន ដែរ ច្រឹប ទីកន្លែងបច្ចុប្បន្ន មាននៅភូមិស្វាយរលំ ឃុំស្វាយរលំ ស្រុកស្អាង នៅខេត្តកណ្ដាល។

កៈ ចឹងជាដំបូងខ្ញុំសូមអរគុណច្រើនមីងដែរបានអោយខ្ញុំសំភាសន៍ពីប្រវត្តិរបស់មីង ហើយការសំភាសន៍ នេះត្រូវបានរៀបចំឡើងដោយសកលវិទ្យាល័យមួយដែរនៅអាមេរិចដែរមានឈ្មោះថាBYU ហើយដោយសារតែសកលវិទ្យាល័យមានគោលបំណងចង់រក្សាពីប្រវត្តិប្រជាជនខ្មែរដើម្បី ទុកអោយកូនចៅ ជំនាន់ក្រោយៗពួកគាត់បានស្គាល់ពីប្រវត្តិរបស់ឪពុកម្ដាយ នឹងប្រវត្តិរបស់ដូចតា ចឹងនៅពេលដែរខ្ញុំបាន សំភាសន៍មីងហើយខ្ញុំនឹងដាក់ការសំភាសន៍មួយនេះទៅក្នុងវេបសាយរបស់សាលាដែរមាន ឈ្មោះថា www.cambodianoralhistories.byu.edu ចឹងហាសមីង ចឹងមីងព្វយល់ព្រមដើម្បីអោយខ្ញុំដាក់ការសំភាសន៍ មួយនេះទៅក្នុងវេបសាយរបស់សាលាដែរទេមីង?

ខៈ អោយដាក់តើ!

កៈ ចឹងសំរាប់ខ្ញុំជាអ្នកដែរសំភាសន៍មីងខ្ញុំមានឈ្មោះថា ជាង ស៊ីអារ ហើយថ្ងៃខែដែរការសំភាសន៍មួយនេះត្រូវបាន ធ្វើឡើងនៅថ្ងៃទី22 ខែ2 នឹងឆ្នាំ2018 គឺបានសំភាសន៍នៅភូមិស្វាយរលំ ឃុំស្វាយរលំ គេហៅភូមិមួយណាមីង?

ខៈ ចា៎!នឹងហើយ

កៈ ស្រុកស្អាង នៅខេត្តកណ្ដាល ចុះមីងសំរាប់ឈ្មោះពេញរបស់មីងនឹងមានឈ្មោះអីគេដែរមីង?

ខៈ មានឈ្មោះដែរ ច្រឹប

កៈ ឈ្មោះដែរ ច្រឹប ចុះមានឈ្មោះហៅក្រៅទេមីង?

ខ៖ អត់មានទេគេហៅតែច្រឹបៗៗនឹងហាស

ក៖  ចុះកាលពីក្មេងៗៗនឹងមានធ្លាប់មាននរណាហៅមីងអីផ្សេងទេនឹង?

ខ៖
គេបានដាក់ឈ្មោះខ្ញុំម៉ែមិនមែនបានដាក់ឈ្មោះអោយចឹងទេខ្ញុំភ្លេចស្អីគេខ្លះទេគាត់បានឈ្មោះម៉ៅ ទៅដល់ពេលហើយបានដាក់ច្រឹបនឹង

ក៖  ចុះមានឈ្មោះហៅក្រៅ ទេមីងឥឡូវនឹងមីងអាយុប៉ុន្មានដែរមីង?

ខ៖  ខ្ញុំអាយុ53ឆ្នាំនឹង

ក៖  ចុះមីងមានដឹងថាមីងកើតនៅថ្ងៃខែឆ្នាំដែរទេ?

ខ៖  ខ្ញុំកើតនៅជំនាន់លុនណុលនៅនៅពេលណុងទំលាក់គ្រាប់មកណាហី

ក៖  អូ៎!ជំនាន់គេទំលាក់លុនណុលហាស?

ខ៖  ខ្ញុំមិនដឹងថាខ្ញុំនៅឆ្នាំប៉ុន្មានទេនឹង ខ្ញុំឆ្នាំប៉ុន្មានចិតប៉ុន្មានដែរអ៊ុំ
ដូចជាប្រហែលអាយុចិតប៉ុន្មាន ដែរអោយស្លួន

ក៖  ចឹងមីងបានកើតនៅក្នុងឆ្នាំ1968ចឹងហាសមីង?

ខ៖  នឹងហើយៗៗៗ!

ក៖  ចុះអ៊ុំមានដឹងថាឆ្នាំច័ន្ទគតិដូចជាឆ្នាំជូត ឆ្លូវ ខាល ថោះអ៊ុំឆ្នាំអីគេដែរ?

ខ៖  ខ្ញុំឆ្នាំរកានឹង

ក៖  មីងឆ្នាំរការអេទេ ខុះមីងបានកើតនៅភូមិអី ឃុំអី ស្រុអីចឹងហាស?

ខ៖  ខ្ញុំស្រុកកំណើត ខ្ញុំនឹងនៅព្រៃកវាំងនឹង

ក៖  នៅព្រៃកវាំង?

ខ៖  នឹងហើយកើតនឹងគេកំពុងទំលាក់គ្រាប់បែកនឹងហាស

ក៖  នៅភូមិអីគេដែរមីង?

ខ៖  ខ្ញុំមិនស្គាល់ភូមិទេអូនខ្ញុំនៅឆ្ងាយណាស់ពីព្រោះតែខ្ញុំបែកមកយូរដែរហើយនឹង

កៈ ប៉ុន្តែដឹងតែនៅស្រុកព្រែកវាំង?

ខៈ នឹងហើយដឹងតែស្រុកព្រែកវាំង

កៈ នៅខេត្តកណ្ដាល់យើងនឹងមែន?

ខៈ ស្រុកព្រែកវាំងនៅណោះ

កៈ ចឹងនៅខេត្តអីគេដែរមីង?

ខៈ នៅខេត្តកណ្ដាលដែរនឹងប៉ុន្តែនៅស្រុកព្រែកវាំងនឹង

កៈ អូ៎!បាទចុះមីងមានបងប្អូនចំនួនប៉ុន្មាននាក់ដែរមីង?

ខៈ ខ្ញុំបងប្អូនរបស់ខ្ញុំនឹងនៅសល់តែ2នាក់នឹងបានស្លាប់អស់ហើយនឹង

កៈ ប៉ុន្តែទាំងអស់តែម្ដងនឹងប៉ុន្មាននាក់ដែរមីង?

ខៈ ទាំងអស់ហោប្អូនរបស់ខ្ញុំនឹង10នាក់

កៈ អូ៎!ចឹងស្លាប់8នាក់ចឹង

ខៈ ចាំ!ខ្ញុំនៅសល់តែ2នាក់ទេប្រុសមួយ ស្រីមួយ

កៈ ប៉ុន្តែមីងជាកូនទីប៉ុន្មានដែរមីង?

ខៈ ខ្ញុំជាកូនបងគេ
មិនមែនបងគេទេខ្ញុំបន្ទាប់បងស្រីខ្ញុំមួយទៀតនឹងបងស្រីខ្ញុំមួយទៀតនឹងបន្ទាប់ខ្ញុំនឹង

កៈ អូ៎!ប៉ុន្តែមីង?

ខៈ ខ្ញុំជាកូនទី3នឹង

កៈ ចុះមីងមានមានចងចាំឈ្មោះបងប្អូនរបស់មីងទាំងស្លាប់ នឹងទាំងរស់ទាំងអស់អត់មីង?

ខៈ ខ្ញុំចាំតើ!

កៈ មីងចាំទាំងអស់ហោសមីងឈ្មោះអីគេខ្លះដែរមីងអាចប្រាប់ខ្ញុំបានទេ?

ខ៖ ឈ្មោះប្អូនរបស់ខ្ញុំទាំងអស់នឹងឈ្មោះផល្លា នឹង ឈ្មោះ ផល្លី ឈ្មោះ ៧ ហើយនឹង មីងការឿន មីការឿននឹងត្រូវជាបងរបស់ខ្ញុំហាស

ក៖ បាទៗមីងបាទ?

ខ៖ នឹងគាត់បងគេបន្ទាប់មកមីគឿន ឈ្មោះមី គា នឹងឈ្មោះ អាចិន ហើយឈ្មោះអាម៉ៅ ហើយខ្ញុំនឹងហើយឈ្មោះច្រឹបនឹងតែម្តងនឹង

ក៖ បាទមីងបាទចុះ?

ខ៖ ហើយប្អូនៗរបស់ពីមុនខ្ញុំមិនសូវដឹងទេនៅតូចៗៗម៉ែខ្ញុំអត់ចឹងគាត់អោយទៅគេហាស

ក៖ បាទមីងបាទ?

ខ៖ នឹងគាត់អោយទៅគេខ្ញុំភ្លេចដែរ

ក៖ ចុះមីងខ្ញុំអាចសុំសួរមួយថាហេតុអីបានជាបងប្អូនរបស់មីងបានស្លាប់ទេ?

ខ៖ បងប្អូនរបស់ខ្ញុំនឹងស្លាប់ពីអាពតនឹង

ក៖ អូ៎!គេយកទៅវៃចោលទាំងអស់ហោសមីង?

ខ៖ ដោយសារតែអត់បាយហូបនឹង

ក៖ ប៉ុន្តែមីងមិនអីទេពេលណុង?

ខ៖ ខ្ញុំមិនអីដែរគាត់អត់បាយហូប

ក៖ ចុះហេតុអីបានជារួចតែមីងចឹងបងប្អូនរបស់មីងអត់រួចចឹងមីង?

ខ៖
រួចតែមីងព្រោះអីទេប្អូនរបស់មីងនឹងមានជំងឺនឹងដល់ពេលមានជំងឺចឹងទៅម៉ែខ្ញុំអោយគេលីជីអីចឹង ទៅណាស់គាត់ទុកកូនចោលអោយគេមើលហាស

ក៖ បាទមីងបាទ?

ខ៖ អោយគេមើលហាសគេមានបានថៃទាំដូចម្តាយណាគាត់ស្លាប់អត់បាយហូបនឹង

ក៖ ប៉ុន្តែរបបអាហារមីងគ្រប់គ្រាន់?

ខ៖ អត់មានគ្រប់គ្រាន់វេទនាដែរនឹងពួកខ្ញុំនឹង

ក៖ ប៉ុន្តែមីងមិនមានឈឺអីទេណាមីង?

ខ៖ អត់មានឈឺអីទេនឹងពួកខ្ញុំធ្វើការងារដែរនឹងទូលអាចម៍គោទៅបឹង
ទៅស្រែទៅអីនឹងខ្ញុំនៅក្មេងៗដែរ នឹងខ្ញុំពីអាពតនឹង

ក៖ អូ៎!បាទមីងចុះពេលណុងមីងគេជំលាសមីងទៅណាដែរមីង?

ខ៖ ខ្ញុំកាលពីអាពតនឹងខ្ញុំនៅត្រឹមនឹងដែរនឹង

ក៖ ប៉ុន្តែកាលពីពតពលនឹងគេជំលាសមីងទៅណាដែរមីង?

ខ៖ កាលពីពលពតនឹងគេជំលាសទៅកន្លែដើមចារនៅក្រោយហោស
កន្លែងភូមិយួនហោសទៅផ្តុំគ្នានៅ
ណុងនឹងគេជំលាសហាសអោយទៅជុំគ្នានៅណុងទាំងអស់នឹង

ក៖ ប៉ុន្តែពេលណុងមីងនៅតូចៗតើហីមីង?

ខ៖ ចា៎!ខ្ញុំនៅតូចៗនឹង

ក៖ មីងចូលកងកុមារ?

ខ៖ ខ្ញុំនៅនេះប៉ុន

ក៖ ដូចជាកងកុមារហើយបានកងនារីមីងពេលណុង?

ខ៖ ខ្ញុំអត់ទាន់កងនារីទេខ្ញុំនៅកុមារនឹងតូចជាងនេះបន្តិចនឹងគេប្រើយើងហាស

ក៖ ប៉ុន្តែគេប្រើយើងអោយធ្វើអីដែរមីង?

ខ៖ គេប្រើអោយលើកអាចម៍គោ ប្រើអោយទូលអាចម៍អីដើម្បីបាចជី
បាចស្រូវបាចអីនឹងនឹងហើយ

ក៖ អូ៎!គេអោយធ្វើដូចមនុស្សធំដែរហោសមីង?

ខ៖ ចា៎!ហើយគេយកយើងទៅនឹង

ក៖ ប៉ុន្តែរបបអាហារកុមារនឹងមនុស្សធំនឹងខុសគ្នាយ៉ាងម៉េចដែរមីង?

ខ៖
ពួកខ្ញុំនិយាយចឹងតែម្តងនឹងក្នុងមួយខែរីកន្លះខែបាយសុទ្ធមួយចានក្រៅពីនឹងសុទ្ធតែបាយលាយក្តួច បាយលាយគល់ល្ហុងនឹងហើយ សម្លអត់មានត្រីទេសុទ្ធព្រលិតនឹង

ក៖ បាទប៉ុន្តែឪពុកម្តាយរបស់មីងនឹងដូចជាគាត់នៅណាដែរមីង?

ខ៖ ឪពុកម្តាយរបស់ខ្ញុំនឹងនៅផ្សេងៗនឹង

ក៖ ប៉ុន្តែពេលណុងគេអោយធ្វើអីគេដែរ?

ខ៖
គាត់នៅផ្សេងៗៗនឹងហើយខ្ញុំនៅផ្សេងៗៗនឹងដល់ពេលដែរយប់ឡើងមកជាមួយម្តាយឪពុកម្តាយ មកផ្ទះនឹង

ក៖ អ៎ូ!ចង់និយាយថាថ្ងៃទៅធ្វើការងារផ្សេងៗដល់ពេលដែរយប់បានយើងមកផ្ទះជុំគ្នា?

ខ៖ ចា៎!ដល់យប់បានជុំគ្នាវិញថ្ងៃនៅផ្សេងៗ

ក៖ អ៎ូ!គេមិនបំបែកយើងអោយនៅឆ្ងាយពីគ្នាផងហោសមីង?

ខ៖ គេមិនបំបែកយើងទេប៉ុន្តែគ្រាន់តែពិបាកហូបចុកណាស់អូនអើយ

ក៖ ប៉ុន្តែម្តាយឪពុកមីងនឹងគេអោយទៅណាទៅពេលណុង?

ខ៖ ទៅកោះគរហោសទៅធ្វើស្អីៗនៅកោះគរនៅណុងហាស

ក៖ កោះគរ?

ខ៖ នឹងហើយកោះគរនៅក្រោមហោស

ក៖ ប៉ុន្តែដូចជា?

ខ៖
ទៅធ្វើការធ្វើអីនឹងណាស់ប្អូនធ្វើការធ្វើអីកាប់ដីកាប់អីប៉ុន្តែពួកខ្ញុំនៅទួលអាចម៍គោទេខ្ញុំនៅក្មេង

ក៖ បាទមីងបាទ?

ខ៖ គេអោយកញ្ចើប៉ុនៗណុងទៅទូលអាចម៍ប៉ុនៗនឹងទៅហូបមួយថ្ងៃបានតែពីរដងទេនឹងមួយថ្ងៃនឹងហូប បានតែពីរដងទេវេទនាណាស់

ក៖ បាទមីងបាទ?

ខ៖ ចាស់ៗចឹងគាត់ឈឺចឹងទៅគាត់មិនមានបាយហូបនឹង

ក៖ អ្ហ៎!គាត់ស្លាប់ដោយសារតែអត់បាយហោសមីង?

ខ៖ នឹងហើយដោយសារតែអត់បាយនឹងហូបអត់មានអីនឹង

ក៖ ប៉ុន្តែចង់និយាយថាម្តាយឪពុករបស់មីងនឹងសព្វថ្ងៃពួកគាត់នៅរស់ដែរតើហីមីង?

ខ៖ ស្លាប់អស់ហើយនឹង

ក៖ គាត់ស្លាប់នៅជំនាន់ណុងដែរហោសមីង?

ខ៖
អត់ទេគាត់ស្លាប់នឹងនៅពេលដែរបានបែកពីអាពតហើយហើយនឹងបានជាគាត់ស្លាប់នឹង

ក៖ អ្ហ៎!គាត់ស្លាប់ដោយសារតែចាស់ៗៗហោសមីង?

ខ៖ ចា៎!គាត់ឈឺគាត់

ក៖ ចុះមីងគិតថាមីងចូលចិត្តលេងអីជាមួយបងប្អូនរបស់មីងកាលពីនៅក្មេងៗៗហាសចូលចិត្តលេងអី គេដែរមីង?

ខ៖
មិនដែលនិយាយអោយត្រង់តែម្តងនឹងមិនដែលលេងអីទេនឹងមិនដែលសប្បាយចិត្តដូចសម័យឥឡូវ នឹងទេនៅតែដាំបាយហូបបុកស្រូវបុកអីចិញ្ចឹមប្អូននឹង
មើលប្អូនថែប្អូនគ្មានបានសប្បាយទេនឹង

ក៖ អ្ហ៎!បាទមីង?

ខ៖ គ្មានដែរបានសប្បាយៗៗដូចក្មេងៗៗសម័យឥឡូវនឹងទេ

កៈ
ចុះប្អូនរបស់មីងដែរមីងគិតថាគាត់នៅរស់ម្នាក់ទៀតនឹងមីងគិតថាគាត់នៅណាដែរមីងឥឡូវនឹង?

ខៈ ប្អូនរបស់ខ្ញុំនឹងទភៅធ្វើការបាត់ហើយនឹង

កៈ ប៉ុន្តែគាត់នៅនឹងដែរហោសមីង?

ខៈ ចាំ!

កៈ គាត់រកស៊ីអីគេដែរមីង?

ខៈ វាចេះតែដើរធ្វើសំណង់ធ្វើស៊ីឈ្នួលគេនឹង

កៈ បាទនៅសល់ប្អូនប្រុសណាមីង?

ខៈ ចាំ!នៅសល់តែប្អូនប្រុសមួយទេខ្ញុំនឹង

កៈ ចុះម្ដាយរបស់មីងនឹងមានឈ្មោះអីគេដែរមីង?

ខៈ ឈ្មោះតែម

កៈ ចុះមានឈ្មោះស្អីគេតែមមីង?

ខៈ ឈ្មោះចេវ តែមនឹង

កៈ គាត់ឈ្មោះ ចេវ តែម?

ខៈ ចាំ!នឹងហើយគាត់ឈ្មោះជាវ តែមនឹង

កៈ ចុះបើសល់សព្វថ្ងៃនឹងគាត់ប្រហែលជាអាយុប៉ុន្មានដែរមីង?

ខៈ ម៉ែរបស់ខ្ញុំនឹងបើសព្វថ្ងៃនឹងគាត់អាយុហុកជាងនឹង

កៈ គាត់អាយុហុកជាងហោសមីង ចុះឪពុករបស់មីងនឹងគាត់មានឈ្មោះអីគេដែរមីង?

ខៈ គាត់ឈ្មោះចេវ

កៈ ឈ្មោះចេវ ហោសមីង?

ខ៖  ចា៎!ឈ្មោះចេវ តែម ម៉ែរបស់ខ្ញុំនឹងឈ្មោះតែម នឹង

ក៖  អូ៎!មានន័យថាឪពុកឈ្មោះចេវ ម្ដាយឈ្មោះតែម?

ខ៖  ចា៎!នឹងហើយ

ក៖  ចុះឪពុកមីងបើមកដល់ឥឡូវនឹងគាត់ប្រហែលជាអាយុប៉ុន្មានដែរមីង?

ខ៖  ឪពុករបស់ខ្ញុំនឹងអាយុហុកជាងនឹង

ក៖  អូ៎!អាយុហុកជាងដូចគ្នាហោសមីង ចុះម្ដាយរបស់មីងនឹងគាត់កើតនៅណាដែរមីង?

ខ៖
ម្ដាយរបស់ខ្ញុំនឹងមិនដឹងថាគាត់កើតនៅណាដែរទេនឹងអូនអើយពីព្រោះតែខ្ញុំអត់ចាំផងមិនដឹងថាគាត់
កើតនៅណានៅណីផងនឹងបើយាយខ្ញុំនៅទៅគាត់ចេះតែដឹងហើយចុះបើយាយរបស់ខ្ញុំអត់នៅផង ចឹងខ្ញុំម៉េចដឹងទៅ

ក៖  អូ៎!ចឹងហោសមីង?

ខ៖  ចឹងខ្ញុំមិនដឹងថាគាត់កើតនៅណានៅណីទេ
ពីព្រោះតែខ្ញុំដឹងក្ដីមកបានតែកន្លែងពិបាកនឹងវេទនា ណាស់ខ្ញុំកើតមកបានកន្លែងវេទនានឹង

ក៖  បាទមីងចុះឪពុករបស់មីងគាត់កើតនៅណាដែរមីងមានដឹងទេមីង?

ខ៖  ឪពុករបស់ខ្ញុំនឹងស្រុកកំណើតនឹងនៅជិតម៉ែរបស់ខ្ញុំនឹងដែរនឹងគាត់នៅព្រៃកវាំង

ក៖  ចឹងគាត់នៅព្រៃកវាំងហោសមីង?

ខ៖  ចា៎!គាត់នៅព្រៃកវាំងស្រុកកំណើតរបស់គាត់នឹងនៅព្រៃកវាំងនឹង

ក៖  ចុះឪពុករបស់មីងនឹងកាលពីគាត់នៅរស់នឹងគាត់ធ្វើអីគេដែរសំរាប់ចិញ្ចឹមជីវិតដែរមីង?

ខ៖  កាលពីគាត់បែកពីអាពតភ្លាមនឹងគាត់ទិញគោលក់

ក៖  អូ៎!គាត់លក់គោហោសមីង?

ខ៖  ចា៎!គាត់ទិញគោលក់នឹង

កៈ ចុះគាត់កាចរឺមួយក៏ស្លូតដែរមីងឪពុកមីងហាស?

ខៈ ឪពុករបស់ខ្ញុំនឹងគាត់ស្លូតនឹង
គាត់ស្លូតទេគាត់មិនដែរទៅរករឿងអ្នកជិតខាងណាទេនឹង

កៈ បាទមីងបាទ?

ខៈ ឪពុករបស់ខ្ញុំនឹងប្តីប្រពន្ធរបស់គាត់ស្លូតណាស់
គាត់មិនដែរតាមការពិតទៅប្តីប្រពន្ធរបស់គាត់នឹងដឹង
តែទៅបាត់ៗទៅរកស៊ីនឹងមកវិញពីរនាក់ប្តីប្រពន្ធគាត់នឹងដឹងតែសំរាននឹង
គាត់មិនដែរដើរទៅផ្ទះនរណា ផងនឹង

កៈ ចុះម្តាយរបស់មីងនឹងគាត់ធ្វើការងារអីសំរាប់ចិញ្ចឹមជីវិតដែរមីង?

ខៈ ម្តាយរបស់ខ្ញុំនឹងពីដើមនឹងគាត់ទិញគោលក់ដែរនឹងគាត់ទិញជាមួយឪពុករបស់ខ្ញុំនឹង

កៈ អូ៎!ចុះគាត់កាចរឺមួយក៏ស្លូតដែរមីង?

ខៈ គាត់ស្លូតទេនឹងហាសក្រុមគ្រួសាររបស់ខ្ញុំនឹងស្លូតៗទេ

កៈ
ចុះមីងមានចងចាំថាកាលពីមីងនៅតូចៗហាសមីងនៅជាមួយឪពុកម្តាយរបស់មីងនឹងមីង
ធ្លាប់មាន អនុស្សាវរីយ៍អីជាមួយគ្នា
មីងធ្លាប់ទៅណាអីជាមួយគ្នាឪពុកម្តាយមីងធ្លាប់ធ្វើអីគេខ្លះដែរជាមួយមីងចឹង ហាសមីង?

ខៈ គាត់នៅតូចៗៗនឹងខ្ញុំចាំបានទេណាស់

កៈ បាទមីងបាទ?

ខៈ គាត់នៅតូចៗៗនឹងគាត់នាំកូនដើរលេង
នឹងហើយគាត់នាំកូនដើរលេងដើរអីកាលណុងស្អីគេគេធ្វើ
តាខ្មៅយើងនេះអាម៉ូតូឡើងជញ្ជាំងអីនឹង

កៈ អូ៎!បាទមីងបាទ?

ខៈ ចា៎!ជិតស្លាប់ទៀតនឹងគេដាក់គ្រាប់បែកនឹង

ក៖  បាទចឹងហោស?

ខ៖  ឪពុករបស់ខ្ញុំគេនាំទៅលេងនឹងថានឹងហើយកូនគេទៅមើលម៉ូតូឡើងជញ្ជាំងនឹង
ទៅមើលម៉ូតូឡើង
ជញ្ជាំងស្រាប់តែឪពុកិរបស់ខ្ញុំនឹងកូនអើយមើលតែប៉ុណ្ណឹងបានងងុយដេកណាស់
ស្រាប់តែខ្ញុំមកផុតមិន ទាន់ប៉ុន្មានផងផ្ទុះ

ក៖  អូ៎!ម៉េចទៅចឹង?

ខ៖  ផ្ទុះនៅភ្នំពេញយើងនឹងផ្ទុះនៅតាខ្មៅយើងនឹងម៉ូតូឡើងជញ្ជាំងនឹង

ក៖  ចុះនរណាគេជាអ្នកបោកគ្រាប់បែកដែរមីង?

ខ៖  ខ្ញុំអត់ដឹងអីផងនឹងកាលណុងខ្ញុំអត់ដឹងទេ

ក៖  ប៉ុន្តែមានអ្នកស្លាប់ទេចឹងមីង?

ខ៖  អូ៎!ស្លាប់ច្រើនហាសណាស់មានច្រើនណាស់នៅតាខ្មៅនឹងហាស

ក៖  អូ៎!ជំនាន់ណាដែរមីង?

ខ៖  ជំនាន់ខ្ញុំនៅក្មេងៗៗនឹងម៉ូតូឡើងជញ្ជាំងពីដើមនឹង

ក៖  បាទៗៗបាទមីងបាទនឹង?

ខ៖
នឹងហើយទៅមើលម៉ូតូឡើងជញ្ជាំងនឹងខ្ញុំដែរដើរទៅមើលគេម្តងនឹងជាមួយឪពុកម្តាយរប
ស់ខ្ញុំនឹង លែងនាំកូនទៅមើលរហូត

ក៖  បាទមីងបាទ?

ខ៖  ពេលណុងខ្ញុំមិនដែរមានក្តីសុខទេនឹង

ក៖  ចុះយាយតាខាងឪពុកនឹងមីងមានស្គាល់ឈ្មោះគាត់ដែរទេ?

ខ៖  ខ្ញុំស្គាល់តែខាងយាយតារបស់ខ្ញុំនឹងឈ្មោះសឹមនឹង ឈ្មោះចាន់ សឹម

ក៖  ចឹងយាយឈ្មោះសឹម នឹងតាឈ្មោះចាន់?

ខ៖ ចាំ!នឹងហើយ

ក៖ នឹងខាងឪពុកណាមីង?

ខ៖ ចាំ!ខាងឪពុកនឹង

ក៖ ចុះខាងម្ដាយវិញមីង?

ខ៖ ខាងម្ដាយខ្ញុំវិញឈ្មោះយាយគុំ នឹងតាបូក ខ្ញុំចាំបាននឹង

ក៖ ចុះដឹងថាពួកគាត់កើតនៅណាមីងមានដឹងទេ?

ខ៖
ខ្ញុំអត់ដឹងទេអូនអើយខ្ញុំអត់ដឹងដែរនឹងខ្ញុំនៅក្មេងៗដែរនឹងមិនដឹងថាគាត់កើតនឹងនៅណានៅណីផង នឹងហាស

ក៖ បាទមីងបាទ?

ខ៖ ខ្ញុំមិនសូវជាដឹងទេពីព្រោះអីខ្ញុំនៅក្មេងៗៗដែរនឹង

ក៖ ចុះមកស្នាក់នៅនឹងយូរនៅមីង?

ខ៖ ស្រុកកំណើតរបស់ខ្ញុំហោសខ្ញុំកើតមកនៅនឹងតែម្ដងនឹង

ក៖ ចឹងមានន័យថានៅប្រហែលជាជាង50ឆ្នាំហើយណាមីង?

ខ៖ ចាំ!នឹងហើយស្រុកកំណើតរបស់ខ្ញុំដឹងក្ដីមកនៅនឹងតែម្ដងនឹង

ក៖ ចុះមីងមានបងប្អូនរឺមួយក៏កូនចៅណារឺក៏បងប្អូនណាដែររស់នៅក្រៅពីស្រុកខ្មែរទេមីង?

ខ៖ អត់ទេអត់មានកូនចៅណាទេមានតែកូនស្រីនេះមួយនឹង
បើមាននៅអាមេរិចនឹងមិនមែនក្រទេក្រ ណាស់អូនអើយ

ក៖ ចុះស្វាមីរបស់មីងមានឈ្មោះអីគេដែរមីង?

ខ៖ ប្ដីរបស់ខ្ញុំហោសប្ដីរបស់ខ្ញុំនឹងឈ្មោះលី

ក៖ ចុះមីងមានចងចាំថាមីងរៀបអាពាហ៍ពិពាហ៍នៅថ្ងៃខែឆ្នាំណាដែរទេមីង?

ខ៖
នេះប្តីក្រោយទេប្តីមុននឹងស្លាប់តាំងពីជំនាន់ណាមកហើយនឹងប្តីរបស់ខ្ញុំមុននឹងស្លាប់កាលពីវៃនឹង កងពលនឹងហាសប្តីរបស់ខ្ញុំនេះឪវានេះ
ស្លាប់តៅមិនដឹងថាទៅណាទៅណើទេបែករហូតបែកគ្នារហូតដល់
ឥឡូវនឹងខ្ញុំទើបតែបានប្តីក្រោយនឹងណាស់

ក៖ អូ៎!បាទមីងបាទ?

ខ៖ នឹងហើយខ្ញុំទើបតែបានប្តីក្រោយនឹងទេ

ក៖ ប៉ុន្តែប៉ុន្តែកាលពីប្តីរបស់មីងចូលស្តីដណ្តឹងមីងនឹងមានជាជំនូនទៅមីងទេ?

ខ៖ ខ្ញុំនិយាយអោយត្រង់តែម្តងនឹងកាលពីដើមគាត់នៅធ្វើជាទាហ៊ាននៅណុងហាស

ក៖ បាទមីងចឹង?

ខ៖ គាត់ធ្វើជាទាហ៊ាននៅនឹងគាត់ចូលស្តីខ្ញុំតាមប្រពៃណីខ្មែរតែម្តងនឹង

ក៖ ប៉ុន្តែមានជាជំនូនទេមីងថ្លៃទឹកដោះអីហាសមីង?

ខ៖ មានតើ!

ក៖ ដូចជាប៉ុន្មានដែរមីង?

ខ៖ បានពីមុននឹងមួយជំឡឹងកន្លះ មួយដំឡើងកន្លះនឹងពីមុនមិនតិចទេ

ក៖ មាសហោសមីង?

ខ៖ ចា៎!មាសនឹង

ក៖ ប៉ុន្តែលឺថាមាសថោកលុយថ្លៃហីមីង?

ខ៖ ដឹងអីដឹងតែកាត់យកមាសមួយដំលើងកន្លះនឹងខ្ញុំដឹងយកជូនម្តាយរបស់ខ្ញុំនឹង

ក៖ ចុះមីងចេះអានរឺមួយចេះសរសេរអក្សរខ្មែរបានប៉ុណ្ណាដែរមីង?

ខ៖ មីងមិនចេះអក្សរទេក្មួយមីងមិនចេះអក្សរទេនឹង

ក៖ អូ៎!មីងមិនដែរបានរៀនផងហោសមីង?

ខ៖  មីងមិនដែរបានរៀនទេនឹង ចុះបើកើតមកភ្លាមបើម៉ែឪក្រមិនចិញ្ចឹមប្អូននៅមើលប្អូននឹង

ក៖  ចុះមីងមានចេះភាសាអីក្រៅពីភាសាខ្មែរដែរទេមីង?

ខ៖  អត់ទេនឹង

ក៖  ចឹងមីងចេះតែខ្មែរទេណាមីង?

ខ៖  ខ្ញុំចេះតែខ្មែរទេនឹង

ក៖
អូ៎!បាទចុះមីងគិតថាមីងធ្លាប់មានអនុស្សាវរីយ៍រឺមួយក៏បងប្អូនរឺមួយក៏មិត្តភក្តិដែរធ្លាប់ធំធាត់មកជាមួយ គ្នាហាសមីងធ្លាប់មានពីមុនទេ?

ខ៖  មានធ្លាប់តើនឹងធ្លប់

ក៖  ចុះមិត្តភក្តិស្និទ្ធិស្នាលរបស់មីងនឹងមីងមាននៅចាំឈ្មោះពួកគាត់ទេ?

ខ៖  គាត់ស្លាប់បាត់ហើយគាត់ស្លាប់អស់ហើយនឹង

ក៖  ប៉ុន្តែពួកគាត់មានឈ្មោះអីគេដែរមីង?

ខ៖  ឈ្មោះទូចនឹង

ក៖  តែម្នាក់នឹងតើហីមីង?

ខ៖  ឈ្មោះទូចនឹង ឈ្មោះម៉ៅ

ក៖  ចុះមានចងចាំអនុស្សាវរីយ៍អីកាលពីមីងនៅក្មេងៗធ្លប់ដើរអីជាមួយពួកគាត់ដែរទេមីង?

ខ៖  ដើរលេងជាមួយគ្នាអីចឹងទៅណាស់ គ្រាន់តែថាបានដើរលេងអីជាមួយគ្នានឹង ធ្វើការអីជាមួយគ្នានឹង

ក៖
ចុះមីងគិតថាតាំងបីក្មេងរហូតមកដល់ពេលនេះមីងគិតថាមីងថ្លាប់បានធ្វើការងារអីគេខ្លះដែរមីង នៅក្នុងជីវិតរបស់មីងហាស?

ខ៖  នៅក្នុងជីវិតរបស់ខ្ញុំហោស?

កៈ បាទមីងបាទ?

ខៈ
ខ្ញុំកាលពីលើកមុននឹងខ្ញុំបានធ្វើការនឹងប្តីខ្ញុំមួយៗនឹងអោយខ្ញុំនៅមើលតែផ្ទះទេនឹងនៅមើលផ្ទះមើល ក្មួយនឹង

កៈ បាទមីងបាទចឹង?

ខៈ រាល់ថ្ងៃនឹងខ្ញុំចិញ្ចឹមក្មួយនឹងកូនរបស់ខ្ញុំស្លាប់បាត់ទៅអស់នឹងហាស

កៈ បាទចឹងមីង?

ខៈ ខ្ញុំចិញ្ចឹមក្មួយនឹងខ្ញុំចិញ្ចឹមក្មួយទាំងសំបុកនឹង
ខ្ញុំកូនស្រីរបស់ខ្ញុំមានតែមួយទេប៉ុន្មានក្មួយរបស់ខ្ញុំនឹង នៅជាមួយខ្ញុំ4-5នាក់នឹង

កៈ ចឹងមីងយកក្មួយមកចិញ្ចឹមហោសមីង?

ខៈ ចាំ!ប្អូនរបស់ខ្ញុំនឹងស្លាប់នឹង

កៈ បាទមីង ចុះមីងធ្លាប់មានលក់ដូរអីទេមីង?

ខៈ អត់ផងក្មួយអើយអត់មានលក់ដូរអីទេក្មួយ

កៈ ចុះមីងធ្លាប់ចិញ្ចឹមសត្វដូចជាមាន់ ទា គោ ក្របីអីទេមីង?

ខៈ ខ្ញុំធ្លាប់តែចិញ្ចឹមគោ

កៈ មានចិញ្ចឹមច្រើនហោសមីង?

ខៈ មានចិញ្ចឹម2-3-4-5ក្បាលអីដែរនឹងចិញ្ចឹមគោទឹមអីដែរនឹងអូនអើយ

កៈ អ្ហូ!បាទមីង
ចុះមីងគិតថាជីវិតរបស់មីងមានការផ្លាស់ប្តូរអីគេខ្លះដែរមីងតាំងពីក្មេងរហូតមកដល់ពេលនេះហាសមីង?

ខៈ មានផ្លាស់ប្តូរអីទេផ្លាស់ប្តូរតែចាស់ហើយនឹង
ចាស់ហើយគ្មានចង់ទៅណាចង់ទៅណីទៀតទេនឹងក្មួយ អើយមិនមានកំលាំងតែម្តងនឹង
នឹងហើយអស់ទឹកចិត្តតែម្តងនឹង

ក៖ ម៉េចចឹងមីង?

ខ៖
អស់ទឹកចិត្តថាគ្មានការងារណាធ្វើចុះបើហាត់នឿពីក្មេងពេកហើយនឹងនិយាយចឹងតែម្តងនឹង
ហាត់ពេក

ក៖ ប៉ុន្តែមីងឥឡូវនឹងមីងគួរសមហើយណាមីង?

ខ៖ ចា៎នឹងហើយ

ក៖ រៀងធូរជាងមុនហើយណាមីង?

ខ៖ នឹងហើយខ្ញុំបានកូនស្រីខ្ញុំនេះនឹង ខ្ញុំបានកូនស្រីរបស់ខ្ញុំនឹងចិញ្ចឹមខ្ញុំនឹង

ក៖ គាត់ទៅធ្វើការហោសមីង?

ខ៖ ចា៎!គាត់ថៃទាំខ្ញុំ

ក៖ គាត់ធ្វើការងារអីគេដែរមីង?

ខ៖ ចា៎!កូនស្រីរបស់ខ្ញុំនឹងប្តីជាអ្នករកស៊ីគេជាអ្នកបើឡាន
ពីមុនខ្ញុំធ្វើការឥឡូវនឹងខ្ញុំពោះធំហើយចឹងខ្ញុំនៅ ផ្ទះនឹង

ក៖ បាទមីងបាទចឹង?

ខ៖ បានកូននឹងអូនអើយ

ក៖ ចុះមីងចូលចិត្តពិសារម្ហូបអីគេដែរមីង?

ខ៖ ខ្ញុំចូលចិត្តទាំងអស់នឹងចូលចិត្តទាំងអស់ជាងគេនឹងចូលចិត្តតែក្រៀមក្រស់នឹងខ្ញុំ

ក៖ អូខេបាទនឹង?

ខ៖ សម្លមិនសូវចូលចិត្តដែរនឹងចូលចិត្តតែក្រៀមក្រស់នឹង
ដូចជាប្រហុកដូចជាអន្លុកអីចឹងហាស

កៈ  បាទមីងចុះមីងគិតថាតាំងពីក្មេងមីងចូលចិត្តលេងល្បែងប្រជាប្រិយ៍អីគេដែរមីង ដូចជាបោះអង្គុញ ចោលឈូង ទាញព្រាត ស្តេចចង់ រឺមួយក៏លេងដណ្តើមស្លឹកឈើអីចឹងហាសមីង?

ខៈ  លេងឈូកកៀបលេងអីនឹង ចាលេងឈូងកៀប លេងបោះអង្គុញនឹងឥឡូវនឹងអត់មានទេអូនអើយ

កៈ  បាទមីងបាទប៉ុន្តែមីង?

ខៈ កាលពីមីងនៅក្មេងៗៗនឹងសប្បាយណាស់

កៈ  គេលេងអីគេខ្លះដែរមីង?

ខៈ  នៅក្រមុំៗហោសលេងចោលឈូង លេងទាញព្រាត លេងដណ្តើមស្លឹកឈើនឹងហើយ

កៈ  ប៉ុន្តែភាគច្រើននឹងមីងទៅលេងនៅណាដែរពេលណុង?

ខៈ
ខ្ញុំលេងនៅម្តុំណុងកាលពីដើមនឹងផ្ទះរបស់ខ្ញុំនឹងនៅមុខហោសលេងសសប្បាយណាស់

កៈ  មិនមែនមីងទៅលេងនៅវត្តណាហីមីង?

ខៈ
អត់លេងនៅនឹងហើយជូនណាទៅវត្តទៅអីចឹងទៅណាស់ដល់ពេលដែរមកពីវត្តទៅលេងទៀតនឹង ថាចូលឆ្នាំនៅសល់មួយខែចឹងលេងសរុបមួយខែនឹង

កៈ  អូ៎!បាទមីងបាទចឹង?

ខៈ  ប៉ុន្តែក្មេងៗឥឡូវនឹងគ្មានទេអូនអើយស្ងាត់ជ្រាប់នឹង

កៈ  គេលែងលេងហើយណាមីង?

ខៈ
ចា៎!គេលេងលេងហើយមិនដូចក្មេងៗៗពីដើមទេនឹងអោយតែព្រលប់ឡើងនឹងដាំបាយមិនទាន់ទេ អាស្គរយើងដុំហោស

កៈ  បាទមីង?

ខ៖ អាស្គរយើងនៅលើដីនោះវៃតុលៗៗៗអូសប្បាយណាស់ពីដើមនឹង

ក៖ សប្បាយហោស?

ខ៖
នាំគ្នារាំហើយនឹងចុះអូនឯងកាលពីមុនគ្មានដៃរមានសំលៀកបំពាក់អីដូចក្មេងសម័យឥឡូវនឹង ណាស់អូន

ក៖ បាទមីងបាទ?

ខ៖ តែម៉ែទិញខោអាវអោយមួយកំផ្លេនឹងយកទៅគក់ទុកស្លៀកយប់កុំអោយប្រលាក់នឹង មានមួយកំផ្លេ គក់ហើយពីដើមនឹង

ក៖ ទុកទៅដើរលេងណាមីង?

ខ៖ ចាំ!ទុកដើររាំងយប់ៗសប្បាយនឹង ដល់ពេលឥឡូវនឹង

ក៖ ចុះមីងគិតថាមីងចូលចិត្តរាំងទេ?

ខ៖ មីងចូលចិត្តរាំដៃរតើមានកម្មវិធីមានអីចឹងមីងចេះតែរាំលេងដៃរនឹង

ក៖ អូ៎!បាទមីង ចុះមីងចេះច្រៀងទេមីង?

ខ៖ កាលពីដើមនឹងមីងចេះច្រៀងដៃរនឹង តែច្រៀងមីងមិនចេះអក្សរចឹងមីងចាំ

ក៖ អូ៎!មីងចងចាំហោស
ចុះមីងគិតថាបទចំរៀងអីដៃរមីងគិតថាមីងចេះច្រៀងហើយមីងចងចាំហាស
បទអីគេដៃរមីងចំណង់ជើងហាស?

ខ៖ នឹងហើយចំណង់ជើងមានតែបទអូនជាវៃមាសនឹងកាលណុង

ក៖ ចុះឥឡូវនឹងមីងអាចដាក់មួយឃ្លាបានទេនឹង

ខ៖ អូ៎!អត់ទេលៃងហើយនឹង

ក៖ អត់ទេនិយាយលេងទេមីង ចុះមីងចូលចិត្តស្តាប់បទចំរៀងទេមីង?

ខ៖ ចូលចិត្តដៃរតើនឹង

កៈ លក្ខណៈជាបទសម័យរឺមួយបទបុរាណដែរមីង?

ខៈ ចូលចិត្តតែបទណាយវ៉ាន់នេតនឹង

កៈ បទណាយវ៉ាន់នេតហោសមីង?

ខៈ ចាំ!នៅសម័យណុងអូនសម័យៗនឹងអ៊ូ!បុរាណនឹង
បុរាណៗៗច្រៀងកំសត់អីនឹងចូលចិត្តណាស់

កៈ
ចុះមីងគិតថាមាននរណាមួយនៅក្នុងក្រុមគ្រួសារមីងចេះលេងឧបករណ៍ភ្លេងដែរទេមីង?

ខៈ គ្មានទេក្មួយអើយអត់មានទេគ្មាននរណាគេចេះទេអត់មានអ្នកចេះទេនឹង

កៈ ចុះផ្ទះរបស់មីងមានលក្ខណៈបែបណាតាំងពីក្មេងរហូតដល់ឥឡូវនឹងហាស
កាលពីក្មេងផ្ទះឈើរឺមួយ ក៏ថ្ម ហើយឥឡូវនឹងផ្ទះយ៉ាងម៉េចដែរ?

ខៈ ផ្ទះឈើដដែលនឹងឈើដដែលនឹង

កៈ ប៉ុន្តែកាលពីក្មេងផ្ទះឈើ ហើយឥឡូវនឹងផ្ទះធំជាងមុនហីមីងរឺយ៉ាងម៉េចដែរ?

ខៈ ដូចតែគ្នានឹងអូនផ្ទះធំនឹងខ្ញុំនិយាយចេះតែម្តងនឹង
ខ្ញុំលក់ធ្វើបុណ្យធ្វើទាន់លក់អោយម្តាយខ្ញុំអស់ ហើយនឹងរាល់ថ្ងៃនឹងខ្ញុំមកនៅជាមួយកូនទេ
ខ្ញុំនៅដោយសារតែកូនរបស់ខ្ញុំទេខ្ញុំគ្មានផ្ទះទេនឹង

កៈ បាទមីងបាទចឹង?

ខៈ ខ្ញុំមកនៅដោយសារតែមួយកូន ហើយកូនរបស់ខ្ញុំនឹងយកខ្ញុំមកនៅនឹង

កៈ ចុះផ្ទះរបស់គាត់នឹងនរណាគេជាអ្នកសាងសងដែរមីងជួលគេ
រឺមួយសាងសងដោយខ្លួនឯងដែរមីង?

ខៈ ខ្ញុំជួលគេធ្វើអោយ

កៈ ចឹងជួលគេធ្វើណាមីង?

ខៈ នឹងស័ង្កសីចឹងតើ នឹងឈើនឹង

កៈ ចុះមីងគិតថាជំនាញអីដែរមិងគិតថាមីងចេះស្ទាត់ជំនាញដែរមីង?

ខៈ អត់មានជំនាញអីទេ

កៈ លក្ខណៈថាលក់ដូរ រឺក៏វេញល្អី កូរស្កុតឆ្នោត ធ្វើរល្អីអីចឹងហាស?

ខៈ កាលពីដើមនឹងធ្វើតែឥឡូវនឹងមីងចាស់ហើយនឹងចូលចិត្តធ្វើស្រែ

កៈ អូ្ន!មីងចូលចិត្តធ្វើស្រែហោសមីង?

ខៈ ធ្វើស្រែ ចិញ្ចឹមគោ អីនឹងហាស

កៈ នេះជាជំនាញរបស់មីងហោសមីង?

ខៈ ចា៎!នឹងហើយនឹង

កៈ ចុះម្តាយឪពុករបស់មីងនឹងគាត់មានធ្លាប់បង្រៀនពីជំនាញអីទៅមីងដែរទេ?

ខៈ គាត់មិនដែរបង្រៀនអីទេគ្រាន់តែថាចេះថៃទាំផ្ទះសំបែង
នឹងមើលកូនមើលចៅអីចឹងទៅលក្ខណៈថា
ធ្វើជាមនុស្សស្រីអោយស្អាតផ្ទះស្អាតសំបែងនឹង ខ្ញុំនៅតែផ្ទះនឹងដែរនឹង

កៈ អូ្ន!បាទមីងបាទ?

ខៈ
កាលពីដើមនឹងខ្ញុំធ្វើស្រែធ្វើអីអូនអើយតែដល់ពេលឥឡូវនឹងខ្ញុំចាស់ហើយខ្ញុំចេះតែឈឺច្រើនដែរនឹង  ខ្ញុំនៅតែផ្ទះទេនឹង

កៈ
ចុះនិយាយពីការលំបាករបស់មីងវិញតាំងពិក្មេងរហូតមកដល់ពេលនេះមីងគិតថាមីងមានការលំបាក អីគេខ្លះដែរមីងនៅក្នុងជីវិតរបស់មីងហាស?

ខៈ
ខ្ញុំកាលខ្ញុំនៅពីក្មេងនឹងខ្ញុំពិបាកណាស់ខ្ញុំពិបាកត្រង់ម្តាយរបស់ខ្ញុំស្លាប់អស់នឹងខ្ញុំចិញ្ចឹមប្អូនរបស់ខ្ញុំ ចាំចិញ្ចឹមប្អូន

កៈ ប៉ុន្តែដល់ពេលណុងមីងអាយុប៉ុន្មានដែរមីង?

ខ៖ ខ្ញុំអាយុជាងម្ភៃនឹង

ក៖ អូ៎!ប៉ុន្តែពេលណុងមីងមិនទាន់មានគ្រួសារទេណាមីង?

ខ៖ ខ្ញុំមានហើយនឹងខ្ញុំមានឪវានេះគេទៅចោលបាត់នឹងហាស

ក៖ បាទមីងបាទ?

ខ៖ ចាំ!ចិញ្ចឹមប្អូន
នឹងចិញ្ចឹមម្តាយស្លាប់ហើយនឹងបានយើងចិញ្ចឹមនឹងម្តាយបានស្លាប់នឹងនៅតូចៗៗនោះ
នឹងហើយដើរបេះត្រកួនដើរបេះព្រលិតអីបានចឹងទៅបានមួយហូបៗៗទៅចិញ្ចឹមបងប្អូនចឹ
ងទៅណាស់

ក៖ ប៉ុន្តែពេលនឹងដាច់ពលពតហើយមែនទេមីង?

ខ៖ ដាច់ហើយយើងមកបេះត្រកួននឹងដែរហាស

ក៖ បាទមីងបាទ?

ខ៖ បេះត្រកួនបេះស្លឹកឈូកហាសកាលណុងហាស
កាលណុងមានទាន់ដូចឥឡូវនឹងណាអូន

ក៖ ពេលណុងឆ្នាំប៉ែតជាងហើមីង?

ខ៖ ចាំ!

ក៖ ចុះមីងគិតថាមានការលំបាកអីផ្សេងពីនឹងទៀតអត់មីងពេលណុងហាស?

ខ៖ លំបាកណាស់លំបាកសព្វបែបសព្វគ្រប់នឹងហាស តែទើបតែខ្ញុំមកស្រណុងនេះនឹង
ស្រណុងត្រឹមខ្ញុំ
ប៉ុន្មានឆ្នាំនឹងស្រណុកនឹងមកនៅជាមួយកូននេះកូនមិនអោយពិបាកនេះនឹង
មកនៅជាមួយកូនស្រីខ្ញុំនេះ នឹងហាស

ក៖ អូ៎!បាទមីងបាទ?

ខ៖ នឹងហើយកូនមិនអោយមែនពិបាកទៀតនឹងឥឡូវនឹងនៅតែផ្ទះមើលកូននឹង

ក៖ មើលចៅអីនឹងហោសមីង?

ខ៖  ចាំ!នៅមើលតែចៅនឹង

ក៖  ចុះមីងគិតថានៅពេលដែរមីងមានក្រុមគ្រួសារហាស
នៅពេលដែរមីងបានក្រុមគ្រួសារដំបូងនឹងមីង គិតថាមីងមានការលំបាកអីគេដែរមីង?

ខ៖  លំបាកយ៉ាងម៉េចលំបាកចិញ្ចឹមកូនវាទៅចោលខ្ញុំបាត់នឹងហាស
ស្លាប់ទៅតាំងពីខ្ញុំទំងន់បាន3ខែនឹង ហាស

ក៖  ប៉ុន្តែកូនតែមួយមែនទេមីង?

ខ៖  នេះកូននឹងប៉ុន្តែខ្ញុំមានតែកូនមួយនឹងគត់នឹង

ក៖  អូ!បាទចឹងមីង?

ខ៖  មានតែកូនមួយនឹងគត់ទៅបាត់ទៅកាលណុងគ្មានទូរស័ព្ទទេក្មួយ
ទៅចេះតែបាត់ប្តីចាំមួយឆ្នាំហើយ នឹងបាត់មួយឆ្នាំហើយបាត់ចាំឡប្តីត្រលប់មកវិញនឹង
តែខ្ញុំចាំដល់ជាង30ឆ្នាំនឹងជិត40ឆ្នាំហើយនឹង

ក៖  អូ!ចឹងមានន័យថាគាត់ស្លាប់រឺមួយក៏គាត់បានបាត់ខ្លួនដែរមីង?

ខ៖  ថាបាត់ខ្លួនតែម្តងទៅរកបងប្អូននៅខេត្តបាត់ដំបងនឹងគេថាអត់មានដឹងមកផងនឹង
បាត់ខ្លួនតែម្តងនឹង ស្លាប់តែម្តងនឹង

ក៖  ពេលណុងគាត់ចេញពីណាទៅហើយគាត់ធ្វើអីគេដែរមីង?

ខ៖  គាត់ធ្វើជាទាហ៊ាននឹង

ក៖  ហើយគាត់ចេញទៅដល់ណាមីងបានគាត់បាត់ខ្លួន?

ខ៖  នៅកងពលលេខ196នឹង

ក៖  ប៉ុន្តែនៅខ្មែរយើងនឹងតើហ៏មីង?

ខ៖  ណាទៅវែទៅដល់កងពលហោសម្តុំអូនឯងមិនស្គាល់ទេនឹង
ម្តុំដីក្រហាមម្តុំផ្ទះតាម៉ុកតាអីនឹងហាស

ក៖  អូ!ផ្ទះតាម៉ុកនៅឧត្តរមានជ័យនឹងហោសមីង?

ខ៖ នឹងហើយនឹងប្តីនៅណុងខ្ញុំបានសរសេរសំបុត្រមួយច្បាប់ទៅមិនឃើញតបហាស ចុះបើយើងមិនមាន ទូរស័ព្ទណា

ក៖ បាទមីងបាទនឹងហោស?

ខ៖ សរសេរទៅរហូតនឹង អោយគេសរសេរអោយទៀតនឹងមិនចេះអក្សរយើងរកប្តីហើយសរសេរទៅបាត់ សរសេរទៅបាត់ដល់ពេលខ្ញុំរកគ្រូមើលខ្ញុំបែកយូរ ខ្ញុំបាត់យូរបានខ្ញុំយកគ្រួសារថ្មីនឹងហាស

ក៖ បាទមីងបាទចឹង?

ខ៖ ខ្ញុំមេម៉ាយយូរឆ្នាំដែរនឹង បានខ្ញុំយកមកនឹងទុកអោយថៃទាំខ្ញុំនឹង

ក៖ ចុះមីងគិតថាទល់ឥឡូវនឹងមីងបានធូរច្រើនជាងមុនហើយណាមីង?

ខ៖ យើងរៀងធូរច្រើនជាងមុនដោយសារតែបានកូននឹង បានកូនមិនអោយម្តាយពិបាកមិនអោយអីចឹង

ក៖ ចឹងមានន័យថាមីងសព្វថ្ងៃនឹងមីងនៅជាមួយកូន?

ខ៖ ចាំ!នឹងហើយ

ក៖ ហើយដូចជាកូនរបស់មីងនឹងដូចជាមើលថៃមីងអីនឹងខ្លះៗដែរទៅណាមីង?

ខ៖ ចាំ!ថៃខ្ញុំ

ក៖ ចុះមីងគិតថាការលំបាករបស់មីងទាំងអស់តាំងពីក្មេងតរហូតដល់ឥឡូវនឹងមីងឆ្លងកាត់វានឹង ដោយរបៀបណាដែរមីង?

ខ៖ ឆ្លងកាត់លំបាកតែម្តងនឹងហាសអូនបេះត្រកួនបេះព្រលិតចឹងទៅ

ក៖ ចង់និយាយថាជំនះឧបសគ្គមួយនឹងហាស?

ខ៖ នឹងហើយចឹង

ក៖ ជំនះដោយរបៀបណាដែរទៅមីង?

ខ៖ ពិបាកតែម្ដងនឹងពិបាកណាស់ខ្ញុំថាពិបាកៗៗហើយនឹង

ក៖ ចុះមីងគិតថាមីងមានការសប្បាយនៅក្នុងឆាកជីវិតរបស់មីងដែរទេមីង?

ខ៖ និយាយអោយត្រង់តែម្ដងនឹងទើបតែសប្បាយនៅពេលដែរចាស់នឹងនេះ

ក៖ អូ៎!មីងសប្បាយរបៀបណាដែរទៅមីងពេលដែរចាស់នឹង?

ខ៖ សប្បាយចេះឃើញគេនឹងហាស ទៅស៊ីការគេ
កូនអោយលុយទៅហូបការហូបអីចឹងទៅ ចេះសប្បាយតាមពួកម៉ាក់បង
គេហៅទៅរាំនឹងចេះតែទៅនឹងគេនឹងឯងចឹងទៅ

ក៖ បាទលក្ខណះជួបជុំគ្នាអីចឹងទៅ?

ខ៖ ចាំ!ជួបជុំគ្នាអីចឹងនឹងហើយខែបុណ្យខែទានអីនឹងចូល
ចូលឆ្នាំចូលទាន់នឹងកូនជូនលុយជូនកាក់នឹង មិនសប្បាយចិត្ត

ក៖ បាទមីងត្រូវ?

ខ៖ មិនយើងធ្វើបុណ្យធ្វើទាននឹងវាសប្បាយនឹង

ក៖
ចុះនៅពេលមីងគិតថាតាំងពីក្មេងហាសមីងចធ្លាប់មានក្ដីស្រម៉ៃអីទេមីងថាមីងធំឡើងមីងចង់ធ្វើអីគេ ចឹងហាសមីង?

ខ៖ ដូចថាចំណាស់នឹងហើយចឹងអត់មានស្រម៉ៃឃើញអីទេអូន

ក៖
អត់ទេតាំងពីក្មេងនៅរៀនហាសកាលនៅប៉ុនៗនេះហាសមីងធ្លាប់មានក្ដីស្រម៉ៃថាមីងចង់ធ្វើជា គ្រូពេទ្យ រឺគ្រូបង្រៀន រឺមួយធ្វើជាអ្នកលក់ដូរអីចឹងហាស?

ខ៖ អត់មានការស្រម៉ៃទេនឹង ចុះបើស្រម៉ៃអីបើនៅជំនាន់ខ្ញុំនឹងវេទនាចង់ស្លាប់ហើយនឹង

ក៖ អូ៎!បាទមីង?

ខ៖ ប៉ុន្តែម៉េចស្រម៉ៃដូចក្មេងឥឡូវនឹងដែរអូន

ក៖ ប៉ុន្តែមីងមិនធ្លាប់គិតថាឃើញគេធ្វើជាគ្រូពេទ្យអីនឹងមីងចង់ធ្វើដែរទេនឹងហោសមីង?

ខ៖  អត់ទេគិតតែពិបាកនៅក្នុងឆាកជីវិត

ក៖  អូ!បាទមីងចុះបើសិនជាចង់អោយមីងផ្ដែផ្ដាំទៅកូនចៅជំនាន់ក្រោយៗរបស់មីងហាស តើមីងចង់ផ្ដែផ្ដាំអីទៅពួកគាត់ដែរមីង?

ខ៖  ចង់អោយថាចង់អោយក្មួយរៀនអោយបានខ្ពង់ខ្ពស់នឹងហើយ អោយចេះមុខរបរអីកុំអោយល្ងង់ដូចជា ខ្ញុំចឹងហាស

ក៖
ចុះបើសិនជាចង់អោយពួកគាត់ជៀសវៀងវិញតើមីងចង់អោយពួកគាត់ជៀសវៀងពីអំពើអីគេដែរ ចឹងហាសមីង អំពើអត់ល្អចឹងហាស?

ខ៖  អំពើអត់ល្អនឹងអំពើគ្រឿងញៀននឹងហើយ

ក៖  ចឹងហោសមីងហោស?

ខ៖  ចា៎!ជៀសវៀងរឿងចឹង ហើយនឹងរឿងលួចប្លន់អើយជៀសវៀងអូន

ក៖  បាទមីងល្អ?

ខ៖  នឹងហើយប្រដៅក្មួយប៉ុណ្ណឹងអោយរៀនអោយសូត្រ

ក៖  បាទមីងចឹងមីងមានអីចង់ផ្ដែផ្ដាំទៅពួកគាត់ទៀតទេមីង?

ខ៖
ផ្ដែផ្ដាំអត់មានអីផ្ដែផ្ដាំទៀតផងនឹងគ្រាន់តែថាសុំអរគុណដែរបានមកសំភាសន៍ខ្ញុំហាសចឹងហាស

ក៖
បាទមីងចឹងជាចុងក្រោយខ្ញុំអរគុណច្រើនមីងដែរបានអោយខ្ញុំសំភាសន៏ពីប្រវត្តិរបស់មីង ហើយការសំភាសន៍ទាំងអស់នេះដែរខ្ញុំបានសំភាសន៍នឹងខ្ញុំនឹងដាក់ការសំភាសន៍នឹងទៅក្នុងវេបសាយរបស់សាលាដែរមាននៅសកលវិទ្យាល័យនៅអាមេរិចចឹងហាសមីង ដើម្បីទុកអោយកូនចៅជំនាន់ក្រោយៗ
ដើម្បីអោយពួកគាត់បានស្គាល់ពីប្រវត្តិរបស់មីងដែរមីងបានរៀបរាប់ពីលើមកមិញចឹងហាសមីង បាទចឹងអរគុណច្រើនមីង៕៕៕